**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សេចក្តីជូនដំណឹង

យោងតាមមតិណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហ៊ុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នាងខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការមេត្តាជ្រាបថា ក្រោយពីឯកឧត្តមរដ្ឋមន្ត្រីបានទាក់ទងសុំការបំភ្លឺជាផ្លូវការពី **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីរួចមក លោកបានបញ្ជាក់ច្បាស់ថា មកដល់ថ្ងៃនេះពុំទាន់មានការណែនាំណាមួយពីទីស្តីការគណៈរដ្ឋមន្ត្រីទៅរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការតាមក្រសួងនីមួយៗ ឱ្យឆ្លើយសម្រេចចិត្តពីស្ថានភាពអនាគតការងាររបស់សាមីខ្លួន ថានៅបន្តឬឈប់ពីការងារដោយមូលហេតុណាមួយនៅឡើយទេ។

ប្រសិនបើមានការជូនដំណឹងជាផ្លូវការពីទីស្តីការគណៈរដ្ឋមន្ត្រីនៅពេលខាងមុខ ឯកឧត្តមរដ្ឋមន្ត្រីនឹងជូនដំណឹងជាចំហ និងផ្លូវការតាមក្រោយ។

អាស្រ័យហេតុនេះ បើមានការណែនាំណាមួយខុសពីសេចក្តីជូនដំណឹងខាងលើនេះ សូមមេត្តាចាត់ទុកជាមោឃៈ។

ថ្ងៃពុធ ៨រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣

**ត.ម. រដ្ឋមន្ត្រី**
**នាយិកាខុទ្ទកាល័យ**

**ម៉ម ចន្ទម៉ារ៉ា**

ផ្លូវវេត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh